ប្រទេសចិន-ខេត្តយូនណាន

ភ្នំពេញប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
No.178

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7909 ថ្ងៃសុក្រ ទី12 ខែមេសា ឆ្នាំ2019

លោក ឆីន ហាវបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា



នៅថ្ងៃទី២៧ ខែមីនា លោក ឆីន ហាវចូលសម្តែងការគួរសម ជាមួយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជានៅរាជធានីភ្នំពេញ

កាលពីថ្ងៃទី២៥ ដល់ទី ៣០ ខែមីនា ឆ្នាំ ២០១៩ លោក ឆីន ហាវ លេខាធិការគណបក្សនៃគណៈកម្មាធិការបក្សកុម្មុយនិស្តចិនខេត្តយូនណាន និងជាប្រធានសភាតំណាងប្រជាជនខេត្តយូនណាន បានអញ្ជើញទៅបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី២៧ ខែមីនា លោកឆីន ហាវ បានចូលសម្តែងការគួរសមជាមួយ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន-សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ។ លោក ឆីន ហាវ បានមានប្រសាសន៍ថា ខេត្តយូនណានបានអនុវត្តន៍យ៉ាងម៉ឺងម៉ាត់តាមការចាត់ចែងពីមជ្ឈិមបក្សកុម្មុយនិស្តចិនសម្រេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយផ្តោះរំលងដែលមានគុណភាពខ្ពស់ ចំណែកប្រជាជនមានអារម្មណ៍កាន់តែច្រើនក្នុងការទទួលនូវសុភមង្គលសុវត្ថិភាព និងផលប្រយោជន៍ ។ បច្ចុប្បន្ន ខេត្តយូនណានកំពុងខិតខំកសាងមជ្ឈមណ្ឌលនាំផ្លូវអភិវឌ្ឍន៍របស់ប្រទេសចិនចំពោះតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ផ្តល់សេវាកម្មនិងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិតាមអនុសាសន៍របស់លោកស៊ី ជីនភីង ពោលគឺ"ការអភិវឌ្ឍសេដ្ឋកិច្ចខេត្តយូនណានត្រូវចាត់ទុកទីតាំងភូមិសាស្ត្រជាឧត្តមភាព និងចាត់ទុកការបើកចំហជាមធ្យោបាយសំខាន់" ។ ខេត្តយូណានទឹងពង្រឹងឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវកិច្ចសហប្រតិបត្តិការពហុវិស័យជាមួយប្រទេសកម្ពុជាដើម្បីរួមចំណែកក្នុងការកសាងសហគមន៍រួមវាសនាចិន-កម្ពុជាដែលមានសារសំខាន់ជាយុទ្ធសាស្ត្រ។ សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ថា កម្ពុជានិងចិនមានទំនុកចិត្តផ្នែកនយោបាយកម្រិតខ្ពស់ សង្ឃឹមថានឹងអាចមានសហគ្រាសខេត្តយូនណានកាន់តែច្រើនមកធ្វើវិនិយោគនៅប្រទេសកម្ពុជា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ"ខ្សែក្រវាត់មួយនិងផ្លូវមួយ" និងពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងប្រទេសកម្ពុជានិងចិន ។ សម្តេចតេជោបានថ្លែងថា ខ្ញុំធ្លាប់ទៅបំពេញទស្សនកិច្ចជាច្រើនលើកនៅខេត្តយូនណាន ហើយសង្ឃឹមថា នឹងអាចទៅទស្សនាខេត្តយូណានម្តងទៀត ។ លោក ប្រាក់ សុខុន មានប្រសាសន៍ថា ការរីកចម្រើននៃប្រទេសចិនបានផ្តល់ផលប្រយោជន៍ដល់ប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀតក្នុងតំបន់ ។ ខ្ញុំសង្ឃឹមថា ប្រទេសកម្ពុជា និងខេត្តយូនណាននឹងអាចពង្រឹងកិច្ចសហប្រតិបត្តិការកាន់តែស្និតល្អុត ។ លោក ឆីន-ហាវ បានជួបពិភាក្សាការងារជាមួយលោកប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជាលោក ខ្សៅ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានកម្ពុជានិងលោក អ៊ឹង ហឿន ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យផ្លាស់ប្តូរទស្សនកិច្ចពាណិជ្ជកម្មវិនិយោគហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ វប្បធម៌ អប់រំ និងសុខាភិបាលជាដើម ។ លោក ឆីន ហាវ បានបញ្ជាក់ថា នៅពេល" ស្នាមញញឹមអង្គរ"ជួបនឹង" ខេត្តយូណានដ៏ចម្រុះពណ៌" មុខជានឹងអាចបញ្ចេញស្នាមញញឹមកាន់តែមានសម្រស់ស្អាតមិនខាន ។

ក្នុងដំណើរទស្សនកិច្ចនេះ ការិយាល័យទំនាក់ទំនងអន្តរជាតិនៃសាលារដ្ឋបាលខេត្តយូនណាន និងអគ្គនាយកដ្ឋានកិច្ចការអាស៊ី-ប៉ាស៊ីហ្វិកនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈស្តីពីការបង្កើតក្រុមការងារសហប្រតិបត្តិការ(ខេត្តយូនណាន) ប្រទេសចិននិង (ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ) ប្រទេសកម្ពុជា ។ ក្រុមហ៊ុនមីឌាវិទ្យុ និងទូរទស្សន៍ខេត្តយូនណាន និងក្រុមហ៊ុនទូរគមនាគមន៍អាស៊ី-អាគ្នេយ៍ (កម្ពុជា)បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើគម្រោងអភិវឌ្ឍន៍កម្មវិធីទូរទស្សន៍បណ្តាញ OTT នៅប្រទេសកម្ពុជា ។ លោក ឆីន ហាវ បានអញ្ជើញទៅទស្សនាគម្រោងសាងសង់តំបន់ច្នៃប្រឌិតវប្បធម៌ចិន-កម្ពុជា ហើយបានតម្រូវឱ្យក្រុមហ៊ុនពាក់ព័ន្ធធានាគុណភាពនៃការសាងសង់និងផ្តល់អាទិភាពដល់ប្រសិទ្ធផលសង្គមដើម្បីរួមចំណែកក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងប្រទេសចិននិងកម្ពុជា។

លោកវ៉ាង វិនធាន ឯកអគ្គរដ្ឋទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជានិងលោក លូយ ជីន ឯកអគ្គរដ្ឋទូតប្រទេសចិនប្រចាំនៅប្រទេសថៃបានអមដំណើរលោក ឆីន ហាវដើម្បីបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជានិងថៃ ៕

ដោយ ឡឺ ធុងស៊ូ និងចាំង យី

ផលិតផលកម្មវិធី APP "ដើរលេងខេត្តយូណាន" ត្រូវកែសម្រួលលើកទី២០ត្រូវប្រកាសឱ្យប្រើប្រាស់

ពេលថ្មីៗនេះផលិតផលកម្មវិធី APP "ដើរលេងខេត្តយូណាន" (២.៩.០) ដែលត្រូវកែសម្រួលលើក ទី២០ បានត្រូវប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ។

ក្នុងអំឡុងពេលកន្លះឆ្នាំបន្ទាប់ពីកម្មវិធី APP "ដើរលេងខេត្តយូណាន "ត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការកម្មវិធី APP នេះបានក្លាយទៅជាប្រព័ន្ធដែលប្រើប្រាស់បច្ចេកទេសឿនឿនបំផុតសម្រាប់ផ្តល់ការណែនាំលើវិស័យទេសចរណ៍ខេត្តយូនណានបង្ហាញទិដ្ឋភាពនៃតំបន់ទេសចរណ៍ផ្តល់សេវាទេសចរណ៍ដែលមានភាពពិតប្រាកដបំផុត និងដោះស្រាយការប្តឹងតវ៉ាដោយប្រសិទ្ធភាពខ្ពស់ជាងគេ ។ គិតមកដល់ថ្ងៃទី ១ ខែមេសាឆ្នាំ ២០១៩ ចំនួនអ្នកប្រើកម្មវិធី APP "ដើរលេងខេត្តយូនណាន" បានកើនឡើងដល់ជាង ២ លាននាក់ ។ កម្មវិធី APP នេះបាន ផ្តល់សេវាកម្មដល់ទេសចរជាតិ និងអន្តរជាតិជាង២០ លានលើក ។

កម្មវិធី APP "ដើរលេងខេត្តយូនណាន "ដែលទើបត្រូវបានកែសម្រួលនេះអាចផ្តល់ជាកដជាសំបុត្រចូលតំបន់ទេសចរណ៍ដែលអាចផ្ទាស់ប្តូរម្តងក្នុងរយៈពេល៦០វិនាទី។ ប្រព័ន្ធនេះមិនគ្រាន់តែអាចបំបាត់ការចំណាយលក់សំបុត្រចូលតំបន់ទេសចរណ៍ខុសច្បាប់ប៉ុណ្ណោះទេហើយអាចធានាដល់សុវត្ថិភាពនៃព័ត៌មានផ្ទាល់ខ្លួនរបស់ទេសចរ និងផ្តល់ការងាយស្រួលដល់ទេសចរក្នុងការស្នើនបាកដចូលតំបន់ទេសចរណ៍ ។

ម៉្យាងទៀត អ្នកទេសចរអាចរក្សាចែករំលែកគ្នានិងធ្វើអត្ថាធិប្បាយអំពីតំបន់ទេសចរណ៍ ឬសុំការជួយនិងប្តឹងប៉ូលិសដោយចុចបិទតង់តែមួយតាមកម្មវិធី APP ដែលត្រូវបានកែសម្រួលជាថ្មី។ ជាពិសេស កម្មវិធី APP ថ្មីនេះបានបន្ថែមនូវទីតាំងនិងផ្លូវធ្វើដំណើរទៅកាន់មន្ទីរពេទ្យ ប៉ុស្តិ៍ប៉ូលិសនិងកន្លែងភ្ញៀសខ្លួន ព្រមទាំងផលិតផលទេសចរណ៍គ្រប់ប្រភេទដើម្បីផ្តល់សេវាកម្មកាន់តែពេញលក្ខណៈដល់ទេសចរ ។

សព្វថ្ងៃផលិតផលទេសចរណ៍ចំនួន ១៣៧ បានត្រូវដាក់បង្ហាញក្នុងកម្មវិធីAPP "ដើរលេងខេត្តយូនណាន" នេះ ដែលមានពាក់ព័ន្ធនឹងការបន្តវិជ្ជាម្ចប្បង្ហាញ់ ដំណើរផ្សងព្រេងនិងការថែរក្សាសុខភាពជាដើមនិងបានគ្របដណ្តប់លើតំបន់ពាយ័ព្យ ឦសាន និងភាគកណ្តាលនៃខេត្តយូនណាន ៕

ដោយ វ៉ាង ហួន

ទេសចរសាកល្បងប្រើ កម្មវិធីAPP "ដើរលេងខេត្តយូណាន" នៅព្រលានយន្តហោះអន្តរជាតិឆាង សួយ ក្រុងគុនមីង

កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គចាក់បញ្ចូលកម្លាំងចលករថ្មីសម្រាប់ការអភិវឌ្ឍន៍នៃប្រទេសកម្ពុជា

ពេលថ្មីៗនេះ ពិធីចុះហត្ថលេខាលើគម្រោងសហប្រតិបត្តិការដែលទទួលការគាំទ្រពីមូលនិធិពិសេសអំពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ បានប្រារព្ធនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ។ លោក វ៉ាង វិនធាន ឯកអគ្គរដ្ឋទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជានិងលោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានធ្វើជាតំណាងនៃភាគីទាំងពីរ និងចុះហត្ថលេខាលើគម្រោងអំពីកិច្ចសហប្រតិបត្តិការ ។ គួរបញ្ជាក់ថា គម្រោងដែលចុះហត្ថលេខាដោយភាគីទាំងពីរមានចំនួន១៩គម្រោងដែលមានពាក់ព័ន្ធទៅនឹងវិស័យអប់រំ ទេសចរណ៍ ការកាត់បន្ថយភាពក្រីក្រនិងការការពារបរិស្ថានជាដើមហើយបានទទួលហិរញ្ញប្បទាន ៧,៦៦ លានដុល្លារ អាម៉េរិក ។

កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គជាយន្តការស្តីពីកិច្ចសហប្រតិបត្តិការអនុតំបន់បែបថ្មីដែលរួមគ្នាបង្កើតដោយប្រទេសចិនកម្ពុជា ថៃ ឡាវ មីយ៉ាន់ម៉ានិងវៀតណាម ។ ភាគីចិនបានផ្តួចផ្តើមឱ្យបង្កើតមូលនិធិពិសេសអំពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ ក្នុងកិច្ចប្រជុំកំពូលលើកទី១ ស្តីពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គឆ្នាំ២០១៦ ហើយបានផ្តល់ប្រាក់ទុន ៣០០ លានដុល្លារអាម៉េរិកដើម្បីគាំទ្រគម្រោងសហប្រតិបត្តិការធុនតូចនិងមធ្យមរបស់ប្រទេសទន្លេឡានឆាង-មេគង្គទាំង៦ ក្នុងរយៈពេល ៦ ឆ្នាំខាងមុខ ។ គម្រោងសហប្រតិបត្តិការអំពីមូលនិធិពិសេសឡានឆាង-មេគង្គក្រុមទី១ របស់ប្រទេសកម្ពុជាដែលមានគម្រោងចំនួន ១៦បានត្រូវចុះហត្ថលេខាជាផ្លូវការនៅខែធ្នូឆ្នាំ ២០១៧ ដែលបានទទួលហិរញ្ញប្បទាន៧,៣លានដុល្លារអាម៉េរិក ។ គិតមកដល់ពេលនេះ គម្រោងកម្ពុជាចំនួន៣៥បានទទួលការគាំទ្រពីមូលនិធិពិសេសអំពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គនេះ ។

លោកវ៉ាង វិនធាន បានមានប្រសាសន៍ថា ក្រោយពីត្រូវបង្កើតឡើងរៀងមកយន្តការស្តីពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គមានឥទ្ធិពលកាន់តែខ្លាំងឡើងៗក្នុងកិច្ចសហប្រតិបត្តិការកម្រិតអនុតំបន់ហើយបានទទួលនូវការចាប់អារម្មណ៍ពីភាគីនានា ។ ភាគីកម្ពុជាបានផ្តល់ការគាំទ្រយ៉ាងសកម្មដល់មូលនិធិពិសេសអំពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គដែលបានធ្វើឱ្យគម្រោងនេះអាចដំណើរការយ៉ាងរលូនហើយនឹងអាចផ្តល់ផលប្រយោជន៍ច្រើនដល់ប្រជាជនខ្មែរលើវិស័យអប់រំការថែរក្សាសុខភាព និងទេសចរណ៍ជាដើម ។ លោក ប្រាក់ សុខុន បានថ្លែងអំណរគុណចំពោះប្រទេសចិនដែលបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់ប្រទេសកម្ពុជា ។ លោកបានមានប្រសាសន៍ថា គម្រោងសហប្រតិបត្តិការថ្មីបានរួះបញ្ចាំងអំពីនិន្នាការអភិវឌ្ឍន៍ល្អនៃកិច្ចសហប្រតិបត្តិការឡាន ឆាង-មេគង្គ ។ គម្រោងទាំងនេះបានផ្តល់កាលានុវត្តភាពច្រើនសម្រាប់ធ្វើ កិច្ចសហប្រតិបត្តិការ ហើយបាននាំមកនូវផលប្រយោជន៍ជាក់ស្តែងនិងបាន លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។

ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនោះគម្រោងទាំង១៦ ដែលកម្ពុជាបានទទួលការគាំទ្រពីមូលនិធិពិសេសអំពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គលើកដំបូងបានដំណើរការអនុវត្តយ៉ាងរលូនដែលបានជំរុញការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងបានលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជនខ្មែរ។ ជាពិសេសការចូលរួមរបស់ភាគីកម្ពុជាបានធ្វើឱ្យកិច្ចសហប្រតិបត្តិការឡាន-ឆាង-មេគង្គទទួលបាននូវសមិទ្ធផលកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំ ។ លោក ប្រាក់ សុខុនបានលើកឡើងថា ទោះបីជាយន្តការស្តីពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គបានត្រូវអនុវត្តន៍មិនទាន់ឃ្យរតែការអនុវត្តជាក់ស្តែងបានសបញ្ជាក់ឱ្យឃើញថាយន្តការនេះ មានឥទ្ធិពលវិជ្ជមានចំពោះវិស័យនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងតំបន់។ លោកបានគូសបញ្ជាក់ថា ការបង្កើនការតភ្ជាប់ផ្លូវអាកាសចរណ៍ក្នុងតំបន់ទន្លេឡានឆាង-មេគង្គជំរុញការអភិវឌ្ឍវិស័យកសិកម្មដោះស្រាយបញ្ហាដីស្រែតាមទន្លេមេគង្គប្រើប្រាស់ព្រៃឈើដោយចីរភាពនិងការគ្រប់គ្រងការនេសាទត្រីជាដើមនឹងអាចផ្តល់ផលប្រយោជន៍ជាក់ស្តែងដល់ប្រទេសនានាក្នុងតំបន់ ៕

ដោយ ចាវ យីភូ និងជឹង ម៉ីឈីន (កាសែតប្រជាជនដេលី)

ប្រទេសចិនទទួលការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការសាងសង់ផ្លូវ



រូបថត: ដោយ ហ៊ូ ស្សៅវយ៉ុង

ក្រោយពីប្រទេសចិនថ្មីត្រូវបានបង្កើតឡើងរៀងមក ប្រទេសចិនបានទទួលនូវលទ្ធផលជាផ្នែផ្កាគួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍបុព្វហេតុសាងសង់ផ្លូវថ្នល់ ។ គិតមកដល់ចុងឆ្នាំ ២០១៧ ប្រទេសចិនបានសាងសង់ផ្លូវល្បឿនលឿន១៣៦.៥០០គីឡូម៉ែត្រ ដែលជាប់លំដាប់លេខ១លើពិភពលោក។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៩ ម៉ាស៊ីនតភ្ជាប់ស្ពានធំមួយគ្រឿងបានដាក់តួស្ពានដ៏ធំមួយផ្នែកដែលមានប្រវែង ៥០ម៉ែត្រនិងទម្ងន់ ២៧០ តោន ដើម្បីតភ្ជាប់នឹងតួស្ពានសំខាន់នៅការដ្ឋានសាងសង់ស្ពានស្បៃវឡុងថានតាមផ្លូវល្បឿនលឿនស្បែនទាន-ថានយី ។ វិធីសាងសង់ស្ពានបែបទំនើបនេះបានត្រូវគេដាក់ឈ្មោះថា"វិធីសាងសង់ស្ពានដោយបង្រួមនូវការផលិតការដឹកជញ្ជូននិងការតភ្ជាប់ស្ពាន" ។ ស្ពានស្បៃវឡុងថាន ដែលមានប្រវែង៨០៤ម៉ែត្រនេះជាស្ពានទី១របស់ប្រទេសចិនដែលសាងសង់ដោយប្រើប្រាស់វិធីបែបទំនើបនេះ៕